ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

## ឯកឧត្តម ប្រាក់ សុខុន
## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដឹកនាំគណៈប្រតិភូ
## អញ្ជើញចូលរួមសន្និបាតទូរស័ព្ទចល័តពិភពលោក "កម្មវិធីថ្នាក់រដ្ឋមន្ត្រី"
## នៅប្រទេសអេស្ប៉ាញ

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ **ឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** ដឹកនាំគណៈប្រតិភូ អញ្ជើញចូលរួមសន្និបាតទូរស័ព្ទចល័តពិភពលោក "កម្មវិធីថ្នាក់រដ្ឋមន្ត្រី" ពីថ្ងៃទី២៧ ខែកុម្ភៈ ដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៥ នៅប្រទេសអេស្ប៉ាញ។

សន្និបាតទូរស័ព្ទចល័តពិភពលោក "កម្មវិធីថ្នាក់រដ្ឋមន្ត្រី" ត្រូវបានប្រារព្ធធ្វើឡើងជារៀងរាល់មួយឆ្នាំម្តង និងមានការអញ្ជើញចូលរួមពីបណ្តារដ្ឋមន្ត្រី, បញ្ញត្តិករ, អ្នកតាក់តែងច្បាប់, និងអ្នកដឹកនាំពីបណ្តាក្រុមហ៊ុនដែលជាប្រតិបត្តិករទូរស័ព្ទចល័តធំៗ សរុបជាងមួយពាន់នាក់ មកពី ១៣០ ប្រទេស ទូទាំងពិភពលោក ដើម្បីពិភាក្សាគ្នាអំពីបញ្ហាប្រឈម និងកាលានុវត្តភាពនៅក្នុងឧស្សាហកម្មទូរស័ព្ទចល័ត។

សម្រាប់ឆ្នាំ ២០១៥ នេះ សន្និបាតទូរស័ព្ទចល័តពិភពលោក "កម្មវិធីថ្នាក់រដ្ឋមន្ត្រី" ត្រូវបានប្រារព្ធឡើងក្រោមប្រធានបទ **"ជម្រុញលើកទឹកចិត្តនវានុវត្តន៍ ដើម្បីការតភ្ជាប់សង្គមយ៉ាងពេញលេញ"** និងផ្តោតកិច្ចពិភាក្សាទៅលើចំណុចសំខាន់ៗ ដូចតទៅ៖

- កាលានុវត្តភាព និងបញ្ហាប្រឈម ក្នុងវិស័យទូរស័ព្ទចល័តនៅទូទាំងពិភពលោក,
- របកគំហើញថ្មីក្នុងវិស័យបច្ចេកវិទ្យាទូរស័ព្ទចល័ត និងតួនាទីរដ្ឋាភិបាល ក្នុងការគាំទ្រវិស័យនវានុវត្តន៍ដើម្បីផលប្រយោជន៍សង្គម,
- ការប្រកួតប្រជែងនៅក្នុងទីផ្សារសេរី, អភិបាលកិច្ចអ៊ីនធឺណិត និងវិសាលគមទូរស័ព្ទចល័ត,
- ការចែករំលែកបទពិសោធន៍ពីតំបន់អាស៊ីប៉ាស៊ីហ្វិក, អាមេរិកឡាទីន, មជ្ឈឹមបូព៌ានិងអាមេរិកខាងជើង, និងអនុតំបន់សាហារ៉ា នៃទ្វីបអាហ្វ្រិក, និង
- ការវាយតម្លៃកម្មវិធីកសាងសមត្ថភាពសម្រាប់បញ្ញត្តិករទូរគមនាគមន៍ចល័តដែលទើបបង្កើតឡើងថ្មីដោយសមាគមប្រតិបត្តិករទូរស័ព្ទចល័តពិសេស ( GSM Association )។

ទន្ទឹមនោះ សន្និបាតទូរស័ព្ទចល័តពិភពលោក "កម្មវិធីថ្នាក់រដ្ឋមន្ត្រី" ក៏នឹងធ្វើពិធីផ្តល់ពានរង្វាន់ចំនួន២ប្រភេទគឺ៖ ទី១.ពានរង្វាន់វិសាលគមន៍សម្រាប់អ៊ីនធឺណិតចល័តល្បឿនលឿន និងទី២.ពានរង្វាន់ភាពជាអ្នកដឹកនាំរបស់រដ្ឋាភិបាលជូនដល់ប្រទេសដែលមានគោលនយោបាយល្អប្រសើរលើវិស័យទូរស័ព្ទចល័តផងដែរ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥